**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៧៥៤៤ មស.បស

**សូមជម្រាបជូន**

- **លោកជំទាវអគ្គលេខាធិការភាគបាលក្រហមកម្ពុជា**
- **ឯកឧត្តមនាយកសាលាតួមិន្ទរដ្ឋបាល**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ**
- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **លោក លោកស្រី គ្រប់ប្រធានអង្គភាព**
- **លោក លោកស្រី ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត**

**កម្មវត្ថុ ៖** សំណើសុំផ្តល់បញ្ជីឈ្មោះមន្ត្រីរាជការដែលត្រូវស្នើសុំដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រសម្រាប់ឆ្នាំ២០២១ និងដំឡើងថ្នាក់តាមវេនជ្រើសរើស និងតាមវេនអតីតភាពការងារសម្រាប់ឆ្នាំ២០២២។

**យោង ៖**
- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីក្រមការ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌលេខាធិការរដ្ឋបាល

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបថា ក្រសួងមុខងារសាធារណៈ និងរៀបចំធ្វើបញ្ជីឈ្មោះមន្ត្រីរាជការ ដែលត្រូវដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រឆ្នាំ២០២១ និង ដំឡើងថ្នាក់តាមវេនជ្រើសរើស តាមវេនអតីតភាព ព្រមទាំងបំពេញព្រឹត្តិបត្រពិន្ទុឡើងថ្នាក់សម្រាប់ឆ្នាំ២០២២។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ធ្វើការជូនដំណឹងដល់ មន្ត្រីក្រោមឱវាទ ដែលត្រូវស្នើសុំដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ ដោយត្រូវធ្វើការបំពេញបែបបទតាមការណែនាំ របស់មន្ត្រីជំនាញ រួចផ្ញើមកនាយកដ្ឋានគ្រប់គ្រងបុគ្គលិក(បន្ទប់ A09) ឱ្យបានមុន**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១** ចំពោះឯកសារស្នើសុំដំឡើងថ្នាក់តាមវេនជ្រើសរើស តាមវេនអតីតភាពការងារ ឱ្យបានមុន**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១** ដើម្បីឱ្យនាយកដ្ឋានជំនាញមានមូលដ្ឋានច្បាស់លាស់ក្នុងការរៀបចំឯកសារដាក់ជូនគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ មន្ត្រីរាជការក្រសួងមុខងារសាធារណៈពិនិត្យ វាយតម្លៃ និងសម្រេច។



ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

<u>ឯកសារតម្រូវ៖</u>

១. <u>ការស្នើសុំដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ សម្រាប់ឆ្នាំ២០២១៖</u>

- ពាក្យស្នើសុំរបស់សាមីខ្លួន(បញ្ជាក់ពីប្រធានអង្គភាព)
- សញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម(បញ្ជាក់អាជ្ញាធរមូលដ្ឋាន)
- តារាងគំរូស្នើសុំដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ
- ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសឡើងថ្នាក់ចុងក្រោយ

២. <u>ការស្នើសុំដំឡើងថ្នាក់តាមវេនជ្រើសរើស និងតាមវេនអតីតភាព សម្រាប់ឆ្នាំ២០២២៖</u>

- តារាងគំរូបញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវដំឡើងថ្នាក់
- ព្រឹត្តិប័ត្រពិន្ទុសម្រាប់ដំឡើងថ្នាក់នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខណ្ឌមន្ត្រីក្រមការ និងក្របខណ្ឌមន្ត្រីលេខាធិការរដ្ឋបាល
- ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសឡើងថ្នាក់ចុងក្រោយ

**សំគាល់៖ ចំពោះមន្ត្រីរាជការដែលបានដាក់ពាក្យស្នើសុំដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រសម្រាប់ឆ្នាំ២០២០រួចរាល់ហើយ ពុំចាំបាច់ដាក់ពាក្យស្នើសុំមកម្តងទៀតទេ នាយកដ្ឋានគ្រប់គ្រងបុគ្គលិករៀបចំជូនក្នុងឆ្នាំ២០២១នេះ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាចូលរួមសហការផ្តល់បញ្ជីឈ្មោះមន្ត្រីរាជការ ដែលត្រូវស្នើសុំដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ តាមវេនជ្រើសរើស និងតាមវេនអតីតភាព មកនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃក្រសួងមុខងារសាធារណៈឱ្យបានទាន់ពេលវេលា។ ក្នុងករណីខកខានមិនបានផ្ញើមកទាន់តាមកាលបរិច្ឆេទខាងលើ សាមីអង្គភាពនីមួយៗ និងសាមីខ្លួនត្រូវទទួលខុសត្រូវដោយខ្លួនឯង ហើយនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នឹងមិនពិនិត្យជូនឡើយ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃច័ន្ទ ១១ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ហ៊ុំ-សុខា**